**សុន្ទរកថា**
**ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ថ្លែងក្នុងពិធីបើក វេទិកាសាធារណៈ**
**"ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០១៦"**
**ទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៥**
**(៩:១០-៩:២៥)**

- ***ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងអគ្គនាយក***
- ***ឯកឧត្តម លោកជំទាវ លោក លោកស្រីជាតំណាងដៃគូអភិវឌ្ឍន៍អង្គការជាតិ និងអន្តរជាតិ***
- ***ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និងក្មួយៗនិស្សិតទាំងអស់ !***

ថ្ងៃនេះ តាងនាមឱ្យថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយ ដោយបានចូលរួមជាអធិបតីក្នុងការបើក **វេទិកាសាធារណៈ** ស្តីអំពី "**ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០១៦**"។ ទន្ទឹមនេះ ខ្ញុំសូមសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅ និងវាយតម្លៃខ្ពស់ចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ដែលបានមកចូលរួមក្នុងវេទិកានេះ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម **វង្សី វិស្សុត** ដែលបានដឹកនាំរៀបចំការងារទាំងអស់នេះ និងអគ្គនាយកដ្ឋានពាក់ព័ន្ធ, អគ្គលេខាធិការដ្ឋាន និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានសហការរួមគ្នា និងខិតខំរៀបចំវេទិកាឱ្យប្រព្រឹត្តទៅបានយ៉ាងរលូនដូចពេលនេះ។

ជាការពិតណាស់ វេទិកាសាធារណៈនេះប្រព្រឹត្តឡើង ក្នុងគោលបំណងចែករំលែកព័ត៌មាន និងការយល់ដឹងអំពីការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងថវិកាឆ្នាំ ២០១៦ ជូនដល់សាធារណជន ក៏ដូចជាតួអង្គពាក់ព័ន្ធផ្សេងៗទៀត ជាពិសេស ផ្តល់ឱកាសឱ្យបានស្វែងយល់កាន់តែច្បាស់អំពីស្ថានភាពនៃការផ្លាស់ប្តូររចនាសម្ព័ន្ធកំណើន និងទស្សនវិស័យសេដ្ឋកិច្ចព្រមទាំងសមិទ្ធផលធំៗ ដែលរាជរដ្ឋាភិបាលសម្រេចបាននាពេលកន្លងមក។ ក្នុងស្មារតីនេះ វេទិកានេះនឹងដើរតួយ៉ាងសំខាន់ក្នុងការលើកកម្ពស់ និងពង្រីកកិច្ចសន្ទនា ជាពិសេស ពង្រឹងតម្លាភាពនៃកិច្ចរៀបចំផែនការអភិវឌ្ឍជាតិ និងការបន្តអនុវត្តការកែទម្រង់កាន់តែស៊ីជម្រៅ ឆ្លើយតបទៅតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា និងការផ្សារភ្ជាប់កាន់តែជិតស្និទ្ធរវាងរាជរដ្ឋាភិបាលជាមួយនឹងមជ្ឈដ្ឋានសាធារណៈ, វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ក្នុងកិច្ចរួមគ្នាអភិវឌ្ឍជាតិ ដោយសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, សមធម៌ និងផ្តល់នូវភាពសុខដុមរមនាដល់ប្រជាពលរដ្ឋកម្ពុជា។

- ***ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិអន្តរជាតិ និងក្មួយៗនិស្សិត!***

ក្នុងទសវត្សរ៍កន្លងមក រាជរដ្ឋាភិបាលកម្ពុជាធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ការគ្រប់គ្រងបាននូវអតិផរ-ណា, ការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ និងការពង្រឹងសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ តាមរយៈការបង្កើនផលិតភាពនៃវិស័យកសិកម្ម, ការកសាងមូលដ្ឋានសេដ្ឋកិច្ចជនបទ, ការពន្លឿនពិពិធកម្មសេដ្ឋកិច្ច ដោយពង្រឹងបរិយាកាសអំណោយផលសម្រាប់ទាក់ទាញការវិនិយោគឯកជន ដែលប្រការទាំងអស់នេះបានបង្កើតការងារជូនប្រជា-ជនកម្ពុជា ពិសេសយុវជនជាច្រើនសែននាក់ ក្នុងមួយឆ្នាំៗ។ ជាក់ស្តែងក្នុងពីរទសវត្សរ៍ ប្រទេសកម្ពុជាត្រូវបានអង្គការអន្តរជាតិ ចាត់បញ្ចូលជាក្រុមប្រទេស **ឯកឧត្តមកំណើន** ទាំងប្រាំបីនៅក្នុងពិភពលោក (Olympians of Growth) ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ និងរឹងមាំ។ នៅឆ្នាំ ២០១៤ នេះ ស្ថានភាពកំណើនសេដ្ឋកិច្ច កម្ពុជាសម្រេចបានក្នុងអត្រា ៧% នាំមុខដោយវិស័យឧស្សាហកម្ម ដែលមានកំណើន ១០,៤% និងវិស័យសេវាកម្មដែលមានកំណើន ៩,១% ធៀបទៅនឹងឆ្នាំ ២០១៣។ ជាមួយគ្នានេះ អតិផរណាមានកម្រិតទាប, អត្រាប្តូរប្រាក់មានស្ថិរភាព ហើយវិស័យហិរញ្ញវត្ថុកាន់តែរីកលូតលាស់ និងរក្សាបាននូវភាពទាក់ទាញវិនិយោគិន។ ផ្អែកលើមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងឆ្នាំ ២០១៤ នេះ សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ ២០១៥ និង ២០១៦ ត្រូវបានព្យាករណ៍ថានឹងបន្តកើនឡើងក្នុងរង្វង់ ៧%។

ទោះជាយ៉ាងណាក៏ដោយ សេដ្ឋកិច្ចកម្ពុជាបានឈានដល់ដំណាក់កាលនៃបរិការណ៍អភិវឌ្ឍន៍ថ្មីមួយ គឺកំពុងក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតទាប និងកំពុងស្ថិតក្នុងដំណើរការនៃការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គម។ ក្នុងន័យនេះ ដើម្បីបន្តធានាកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណ **៧%** ក្នុងមួយឆ្នាំ ដោយបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ ដែលជាមូលដ្ឋានមិនអាចខ្វះបានសម្រាប់ការបង្កើតការងារ និងឱកាសរកប្រាក់ចំណូលសមរម្យ ព្រមទាំងបន្តចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនទូទៅ កម្ពុជាត្រូវតែបន្តធ្វើពិពិធកម្មសេដ្ឋកិច្ច តាមរយៈការពង្រឹង និងពង្រីកវិស័យជាមូលដ្ឋានដែលជំរុញកំណើនសេដ្ឋកិច្ច ជាពិសេសទៅលើវិស័យឧស្សាហកម្មធុនស្រាល និងមធ្យម។ ជាមួយគ្នានេះ កម្ពុជាក៏កំពុងស្ថិតនៅក្នុងបរិបទសេដ្ឋកិច្ច និងនយោ-បាយតំបន់ និងសកលដែលកំពុងប្រែប្រួលឥតឈប់ឥតឈរ។ ក្នុងន័យនេះ ប្រទេសកម្ពុជាត្រូវជំរុញការកែទម្រង់ឱ្យបានកាន់តែស៊ីជម្រៅថែមទៀត ហើយអនុវត្តឱ្យបានកាន់តែមានប្រសិទ្ធភាព ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ និងបង្កើនភាពប្រកួតប្រជែងរបស់យើងក្នុងតំបន់ និងក្នុងពិភពលោក ពិសេសសហគមន៍សេដ្ឋកិច្ចអាស៊ាន។

- ***ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិអន្តរជាតិ និងក្មួយៗនិស្សិត!***

សម្រាប់ឆ្នាំ ២០១៦ **ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ**: មានគោលដៅធានាឱ្យបានកំណើនសេដ្ឋកិច្ចក្នុងកម្រិត ៧% តាមរយៈការពង្រឹងភាពប្រកួតប្រជែងទាំងក្នុងការទាក់ទាញវិនិយោគ, ការបង្កើនផលិតភាពគ្រប់វិស័យ ជាពិសេសក្នុងវិស័យកសិកម្ម, ការជំរុញការធ្វើពិពិធ-កម្មសេដ្ឋកិច្ចក្នុងសន្ទុះថ្មី, ការគ្រប់គ្រងហានិភ័យនៃកំណើន ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ

និងការបន្តផ្តោតកាន់តែស៊ីជម្រៅទៅលើការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាសាធារណៈ ដើម្បីសម្រេចបាននូវគោលបំណងគោលនយោបាយគន្លឹះៗ និងបន្តចលនការនៃការកែទម្រង់ឱ្យរន្ទើនទៅមុខ ដូចដែលបានដាក់ចេញនៅក្នុង **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣** ដើម្បី **កំណើន, ការងារ, សមធម៌** និង **ប្រសិទ្ធភាព** នៅកម្ពុជា និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញ **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ២០១៥-២០២៥** ដែលមានគោលដៅពង្រឹង និងពង្រីកមូលដ្ឋានសេដ្ឋកិច្ចជាតិ តាមរយៈការជំរុញផលិតកម្មការលើកកម្ពស់ផលិតភាពភាពប្រកួតប្រជែងនៃវិស័យកម្មន្តសាល ជាពិសេសសម្រាប់ភាពចាំបាច់របស់កម្ពុជា ក្នុងការរៀបចំខ្លួនដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងក្នុងក្របខ័ណ្ឌពិភពលោក និងតំបន់ និងការចាប់ផ្តើមនៃសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥។

ដើម្បីសម្រេចនូវគោលដៅទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បន្តអនុវត្ត **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** និងការកែទម្រង់រចនាសម្ព័ន្ធចាំបាច់នានា ព្រមទាំងបន្តជំរុញនូវគោលនយោបាយសារពើពន្ធ ដោយផ្តោតជាសំខាន់លើរដ្ឋបាលចំណូល និងការកែលម្អអភិបាលកិច្ចព្រមទាំងការរឹតបន្តឹងចំណាយ ដើម្បីកាត់បន្ថយឱនភាពថវិកាឱ្យមកត្រឹមកម្រិតមួយសមរម្យ និងបង្កើន**លំហថវិកា**។ ក្នុងស្មារតីនេះ ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៦ នឹងជំរុញការអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨** សម្រេចឱ្យបាននូវការប្រមូលចំណូលចរន្តសរុបបន្ថែមឱ្យបាន **0,៥ ពិន្ទុភាគរយនៃផ.ស.ស.**ក្នុងមួយឆ្នាំ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបន្តខិតខំប្រឹងប្រែងក្នុងកាកៀរគរចំណូលរយៈពេលខ្លី និងមធ្យមឱ្យបានកាន់តែច្រើនថែមទៀត តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការនានាដែលបានកំណត់ក្នុង **គោលនយោបាយកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**។ ជាពិសេស វិស័យពាក់ព័ន្ធជាអាទិភាពនាពេលបច្ចុប្បន្ននិងក្នុងរយៈពេលមធ្យមខាងមុខនេះនឹងផ្តោតលើវិធានការកែទម្រង់រដ្ឋបាល, ការកែលម្អគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ព្រមទាំងការពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃ។

ទន្ទឹមនេះ ក្របខ័ណ្ឌចំណាយនឹងផ្តោតសំខាន់ដល់ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការបន្តដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ ដើម្បីឱ្យមន្ត្រីរាជការទាំងអស់ទទួលបាន**ប្រាក់បៀវត្សច្រើនជាង ១លានរៀល ត្រឹមឆ្នាំ ២០១៨**។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏នឹងបន្តតម្រង់ទិសដៅនៃគោលនយោបាយថវិកា ដោយធ្វើការវិភាជន៍ឆ្ពោះទៅរកផលិតភាព, ការបង្កើនភាពប្រកួតប្រជែង និងមានលក្ខណៈបរិយាប័ន្ន ក្នុងនោះបន្តការយកចិត្តទុកដាក់បង្កើនចំណាយលើការ**អភិវឌ្ឍជំនាញ**សម្រាប់យុវជន, **ការពង្រឹងវិស័យអប់រំ,** ការលើកកម្ពស់**វិស័យសុខាភិបាល,** ការបង្កើន**ផលិតភាពកសិកម្ម,** ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការបន្តរៀបចំបណ្តាញផ្គត់ផ្គង់ឡូជីស្ទីកឱ្យមានលក្ខណៈរលូនជាដើម។ ទន្ទឹមនេះ **ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៦** គឺធ្វើឡើងក្នុងគោលដៅរៀបចំ និងតម្រង់ទិសគោលនយោបាយឱ្យស្រមតាមវិស័យ និងសកម្មភាពរបស់ក្រសួងនានា។

ជាមួយគ្នានេះ ផែនការយុទ្ធសាស្ត្រថវិកាក៏គិតគូរយ៉ាងម៉ត់ចត់អំពីតម្រូវការសម្រាប់ការអនុវត្ត **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ២០១៥-២០២៥** ប្រកបដោយជោគជ័យតាមការកំណត់ក្នុងយុទ្ធសាស្ត្រផងដែរ ។

- ***ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិអន្តរជាតិ និងក្មួយៗនិស្សិត!***

មុននឹងបញ្ចប់ ខ្ញុំសូមបញ្ជាក់ជាថ្មីម្តងទៀតថា ពេលនេះជាងពេលណាៗទាំងអស់ ដែលយើងត្រូវធ្វើការរួមគ្នាក្នុងវប្បធម៌មិពិគ្រោះយោបល់ និងសហប្រតិបត្តិការកាន់តែ ***ស៊ីជម្រៅក្នុងលក្ខណៈស្ថាបនា*** ដើម្បីសន្តិភាព, ស្ថិរភាព, ការអភិវឌ្ឍ និងវិបុលភាពទៅថ្ងៃអនាគតនៅកម្ពុជា។ ការអនុវត្តការកែទម្រង់ក្នុងគ្រប់វិស័យរបស់យើងនឹងមិនអាចសម្រេចទៅបានឡើយ ប្រសិនបើមិនមានការកែលម្អកិច្ចសហការ និងសហប្រតិបត្តិការរវាងក្រសួង និងស្ថាប័ននានា, ការពង្រឹង ស្ថាប័នក្នុងរយៈពេលវែង និងសមត្ថភាពវិជ្ជាជីវៈរបស់មន្ត្រី ដើម្បីជំរុញ និងអនុវត្តការកែទម្រង់ និងប្រព័ន្ធរដ្ឋបាលប្រកបដោយប្រសិទ្ធភាព។ ក្នុងន័យនេះ ខ្ញុំក៏ជឿជាក់ថា យើងនឹងទទួលបាននូវមតិយោបល់ និងអនុសាសន៍ដ៏ល្អប្រកបដោយការស្ថាបនាពីវេទិការបស់យើងនាពេលព្រឹកនេះ។

ជាចុងក្រោយ ខ្ញុំសូមជូនពរឱ្យវេទិកានៅថ្ងៃនេះប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្មួយៗទាំងអស់ ដែលមានវត្តមាននៅទីនេះ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរគុណ !***